# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
# នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 08-May-2013, 13:55
CMS/CFO: Sann Rada

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ៖ ០០២/១៩-០៩-២០០៧-អវតក/អជសដ

ភាគីដាក់ឯកសារ៖ លោក **ខៀវ សំផន**

ដាក់ជូន៖ អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម៖ **បារាំង**

កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី៨ ខែ ឧសភា ឆ្នាំ ២០១៣

## ចំណាត់ថ្នាក់ឯកសារ

ចំណាត់ថ្នាក់ឯកសារស្នើឡើងដោយភាគីដាក់ឯកសារ៖ **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះសាលាដំបូង៖ សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់៖

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្ដោះអាសន្ន៖

ឈ្មោះមន្ត្រីទទួលបន្ទុកផ្នែកសំណុំរឿង និងឯកសារ៖

ហត្ថលេខា៖

---

# សំណើលើកទី២ សុំដាក់បញ្ចូលអង្គបទដកស្រង់ចេញពីសៀវភៅ លោក Marcel LEMONDE ទៅក្នុងកិច្ចពិភាក្សាដេញដោល

---

ដាក់ដោយ៖

**មេធាវីការពារក្ដីលោក ខៀវ សំផន**

មេធាវី គង់ សំអុន

មេធាវី Anta GUISSÉ

មេធាវី Arthur VERCKEN

មេធាវី Jacques VERGÈS

ដាក់ជូន៖

**អង្គជំនុំជម្រះសាលាដំបូង៖**

ចៅក្រម និល ណុន

ចៅក្រម Silvia CARTWRIGHT

ចៅក្រម យូរ ឧត្តារា

ចៅក្រម Jean-Marc LAVERGNE

ចៅក្រម យ៉ា សុខន

**ជំនួយការ៖**
លោកស្រី សេង សុជាតា
កញ្ញា Marie CAPOTORTO
កញ្ញា Shéhérazade BOUARFA
កញ្ញា Mathilde CHIFFERT
កញ្ញា Vera MANUELLO
កញ្ញា អ៊ូច ស្រីផាត
លោកស្រី សុគន្ធ មោនីកា
លោក Pierre TOUCHE
កញ្ញា Blandine ZELLER

**សហព្រះរាជអាជ្ញា៖**
លោកស្រី ជា លាង
លោក Andrew CAYLEY

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់**

**ក្រុមមេធាវីការពារក្តីទាំងអស់**

# គោរពជូនអង្គជំនុំជម្រះសាលាដំបូង

១. នៅថ្ងៃទី ១៥ ខែមីនា ឆ្នាំ២០១៣ មេធាវីការពារក្តីរបស់លោក នួន ជា បានដាក់សំណើទៅអង្គជំនុំជម្រះតុលាការកំពូល ដើម្បីសុំពិចារណាភស្តុតាងបន្ថែម ក្នុងក្របខណ្ឌបណ្តឹងឧទ្ធរណ៍មួយ[1]។ នោះជាករណីសម្រង់អត្ថបទពីក្នុងស្នាដៃថ្មីមួយរបស់លោក Marcel LEMONDE អតីតសហចៅក្រមស៊ើបអង្កេតនៃ អ.វ.ត.ក [2]។

២. ថ្ងៃទី ១០ ខែមេសា ឆ្នាំ២០១៣ មេធាវីការពារក្តី លោក ខៀវ សំផន ស្នើសុំដាក់បញ្ចូលអត្ថបទមួយចំនួនដកស្រង់ពីសៀវភៅដដែលនេះ ដែលមានភាពពាក់ព័ន្ធនឹងសំណើសុំដោះលែងរូបលោកឱ្យនៅក្រៅឃុំ[3] ទៅក្នុងកិច្ចពិភាក្សាដេញដោល[4]។

៣. ថ្ងៃនេះ មេធាវីការពារក្តីធ្វើការស្នើសុំជាលក្ខណៈទូទៅ ដាក់បញ្ចូលសម្រង់អត្ថបទរបស់លោក Marcel LEMONDE នេះ ទៅក្នុងកិច្ចពិភាក្សាដេញដោល និងទទួលយកឯកសារទាំងនេះធ្វើជាឯកសារភស្តុតាង ដោយអនុលោមតាម វិធាន ៨៧.៤ នៃវិធានផ្ទៃក្នុង។[5]

៤. ដោយសារសៀវភៅនេះចេញផ្សាយនៅខែមករា ឆ្នាំ២០១៣ ដូច្នេះគេមិនអាចនឹងរកសៀវភៅនេះមកប្រើប្រាស់បាន មុនពេលបើកសវនាការ ហើយទោះជាក្រុមមេធាវីប្រឹងប្រែងយ៉ាងណា ក៏មិនអាចស្វែងយល់ពីសៀវភៅនេះបាន មុនពេលស្នាដៃនេះចេញផ្សាយបានឡើយ។

៥. អត្ថបទដកស្រង់ដែលត្រូវបានជ្រើសរើសពិតជាមានសារប្រយោជន៍ដល់ការស្វែងរកការពិត និងបំពេញនូវរាល់ល័ក្ខខ័ណ្ឌតម្រូវដែលមានចែងនៅក្នុងកថាខណ្ឌទី៣ នៃវិធាន ៨៧[6]។ អត្ថបទ

---

[1] សំណើសុំពិចារណាភស្តុតាងបន្ថែម ចុះថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០១៣ឯកសារ **E189/3/1/7** “សំណើសុំរបស់ លោកនួន ជា”។

[2] *Un juge face aux Khmers rouges* និពន្ធដោយលោក Marcel LEMONDE សហការជាមួយលោក Jean REYNAUD គ្រឹះស្ថានបោះពុម្ពផ្សាយ Editions du Seuil ខែ មករា ឆ្នាំ ២០១៣ (“សៀវភៅរបស់លោក Marcel LEMONDE”)។

[3] សំណើសុំដោះលែងលោក ខៀវ សំផន ឱ្យនៅក្រៅឃុំជាបន្ទាន់ ដោយដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ចុះថ្ងៃទី ២៩ ខែមីនា ឆ្នាំ ២០១៣ ឯកសារ E275

[4] សំណើលើកទី១ សុំដាក់បញ្ចូលអត្ថបទដកស្រង់ចេញពីសៀវភៅលោក Marcel LEMONDE ទៅក្នុងកិច្ចពិភាក្សាដេញដោល ថ្ងៃទី ១០ ខែមេសា ឆ្នាំ ២០១៣ ឯកសារ E280 (“ការស្នើសុំលើកទី១”)

[5] “ក្នុងកំឡុងពេលសវនាការ តាមគំនិតផ្តួចផ្តើមរបស់អង្គជំនុំជម្រះ ឬតាមការស្នើសុំរបស់ភាគី អង្គជំនុំជម្រះអាចកោះហៅ ឬស្តាប់ចម្លើយបុគ្គលណាម្នាក់ក្នុងឋានៈជាសាក្សី ឬទទួលយកនូវភស្តុតាងថ្មី ដែលមានប្រយោជន៍សម្រាប់នាំមកនូវការស្វែងរកការពិត។ គ្រប់ភាគីដែលបានស្នើសុំត្រូវបញ្ជាក់មូលហេតុនៃការស្នើសុំនេះឱ្យបានច្បាស់លាស់។ អង្គជំនុំជម្រះនឹងធ្វើសេចក្តីសម្រេចចំពោះការស្នើសុំនោះ ផ្អែកតាមខ្លឹមសារដែលមានចែងនៅក្នុងវិធាន ៨៧(៣) ខាងលើ។ ភាគីដែលស្នើសុំត្រូវតែធ្វើឱ្យអង្គជំនុំជម្រះជឿជាក់ថា សក្ខីកម្ម ឬភស្តុតាងដែលបានស្នើសុំនោះ ពុំអាចរកបាននៅមុនពេលការចាប់ផ្តើមជំនុំជម្រះ”។

ដកស្រង់ទាំងអស់នោះ ជួយក្នុងការវាយតម្លៃលើភាពគួរឱ្យទុកចិត្តបាននៃភស្តុតាងនានាដែលទទួលបានក្នុងអំឡុងពេលស៊ើបអង្កេត។ នៅក្នុងសៀវភៅរបស់គាត់នេះ លោក LEMONDE បានរៀបរាប់ពីល័ក្ខខ័ណ្ឌដំណើរការនៃការស៊ើបអង្កេតលើសំណុំរឿង ០០២ ព្រមទាំងបានផ្តល់នូវការវាយតម្លៃរបស់គាត់លើភស្តុតាងនានាដែលគាត់បានទទួលនាពេលនោះ។

## I. **លក្ខខណ្ឌដែលភស្តុតាងត្រូវបានទទួលមកក្នុងពេលស៊ើបអង្កេត**

៦. នៅក្នុងស្នាដៃរបស់លោក អតីតសហចៅក្រមស៊ើបអង្កេត បានបង្ហាញពីការលំបាកដែលលោកបានជួបប្រទះក្នុងពេលស៊ើបអង្កេត។ លោក LEMONDE បានរៀបរាប់ថា តើលោកស្ថិតនៅក្នុងស្ថានភាពមិនអាចទទួលបានភស្តុតាងសំខាន់ៗយ៉ាងដូចម្តេចខ្លះ។ លោកក៏បានលើកឡើងផងដែរនូវបញ្ហានៃការបកប្រែ ព្រមទាំងការសម្រេចជ្រើសយកយុទ្ធសាស្ត្រដែលប៉ះពាល់យ៉ាងខ្លាំងដល់អត្ថប្រយោជន៍របស់ជនជាប់ចោទ។

### **ក. ភាពមិនអាចទទួលបានភស្តុតាងសំខាន់ៗ**

៧. ក្នុងស្នាដៃរបស់លោក លោក LEMONDE បានបង្ហាញថា លោកពុំអាចទទួលបាននូវភស្តុតាងសំខាន់ៗ ដោយសារតែមូលហេតុនយោបាយ និងប្រហែលជាដោយសារតែខ្វះភាពលំអៀង។

#### ១. **មូលហេតុនយោបាយ**

៨. បើតាមលោកអតីតចៅក្រមស៊ើបអង្កេត ការដែលមិនអាចទទួលបានភស្តុតាងសំខាន់ៗ គឺដោយសារតែរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលសហរដ្ឋអាមេរិក។

ក. រដ្ឋាភិបាលកម្ពុជា

---

[6] “(...) អង្គជំនុំជម្រះសាលាដំបូងអាចបដិសេធចំពោះពាក្យសុំឱ្យពិនិត្យភ័ស្តុតាង បើយល់ឃើញថា៖ ក) មិនជាប់ពាក់ព័ន្ធ ឬជាការស្នើសុំជាន់គ្នា, ខ) មិនអាចរកបានក្នុងរយៈពេលសមស្របណាមួយ, គ) មិនសមស្របសម្រាប់បញ្ជាក់អង្គហេតុដែលជាគោលដៅនៃការស្នើសុំពិនិត្យភ័ស្តុតាង, ឃ) ច្បាប់មិនអនុញ្ញាត ឬ ង) មានចេតនាពន្យារកិច្ចដំណើរការនីតិវិធី ឬគ្មានប្រយោជន៍”។

៩. នៅក្នុងស្នាដៃរបស់លោក លោក LEMONDE បានបង្ហាញជាសាធារណៈពីការជ្រៀតជ្រែករបស់រដ្ឋាភិបាលកម្ពុជា នៅក្នុងនីតិវិធី និងការស៊ើបអង្កេត។ ដោយសារតែការជ្រៀតជ្រែក និងការដាក់សម្ពាធ សាក្សីសំខាន់ៗ *"ដែលគេត្រូវស្ដាប់ចម្លើយជាទីបំផុត ធ្វើឱ្យគេមិនបាន"*[7] មិនត្រូវបានស្ដាប់ដោយសហចៅក្រមស៊ើបអង្កេតឡើយ ហើយក៏នឹងមិនមកបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងឡើយ។

១០. ក្រុមមេធាវីការពារក្ដី លោក ខៀវ សំផន សូមយោងទៅអំណះអំណាងដែលបានលើកឡើងយ៉ាងលម្អិត ដោយក្រុមមេធាវីការពារក្ដី លោក នួន ជា ចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល[8] ហើយក៏សូមដាក់បញ្ចូលសម្រង់អត្ថបទដែលបានជ្រើសរើស ទៅក្នុងកិច្ចពិភាក្សាដេញដោល ចំពោះមុខអង្គជំនុំជម្រះសាលាដំបូង។

ខ. រដ្ឋាភិបាលសហរដ្ឋអាមេរិក

១១. លោក LEMONDE បានបង្ហាញជាសាធារណៈពីការជួបការលំបាក ដែលបង្កឡើងដោយរដ្ឋាភិបាលសហរដ្ឋអាមេរិក ដែលញ៉ាំងឱ្យលោកសរសេរដូចខាងក្រោម៖

*"លោក Greg Lawless (...) ដែលទទួលបន្ទុកបញ្ហានយោបាយនៅស្ថានទូតអាមេរិក ដែលធ្លាប់មកជួបនឹងខ្ញុំនៅសាលាក្ដី បានបញ្ជាក់ប្រាប់ខ្ញុំថា ការស្នើសុំជាផ្លូវការនេះ មិនមែនមកពីស្ថានទូតនោះឡើយ ហើយក៏មិនមែនមកពីខាងរដ្ឋាភិបាលដែរ តែគឺមកពីសភាអាមេរិកាំងតែម្ដង។ ក៏ប៉ុន្តែ ក្រោយមក ខណៈដែលយើងព្យាយាមចង់បានឯកសារពីទីភ្នាក់ងារ សេអ៊ីអា ស្ដីពីប្រទេសកម្ពុជា ដែលមានព័ត៌មានសំខាន់ៗ សម្រាប់ការស៊ើបអង្កេត ការរារាំងក៏បាននាំឆ្ពោះទៅរកទីបញ្ចប់មួយ គឺថាយើងស្ទើរតែមិនទទួលបានអ្វីទាំងអស់ ក្រៅតែពីរូបថតប៉ុន្មានសន្លឹក ដែលបង្ហាញពីក្រុងភ្នំពេញដែលគេជម្លៀសមនុស្សចេញអស់ នៅថ្ងៃទី១៨ ខែមេសា ឆ្នាំ១៩៧៥។ ឯកអគ្គរដ្ឋទូតពេញសមត្ថភាពនៃសហរដ្ឋអាមេរិក ដែលធ្វើការប្រឆាំងនឹងឧក្រិដ្ឋកម្មសង្គ្រាម (...) បានប្រគល់រូបទាំងនោះយ៉ាងមានមោទនភាព ប្រៀបដូចជាពានរង្វាន់អ្វីមួយដ៏សំខាន់។ តាមការពិត លោកមិនមែនមិនដឹងនោះទេថា ឯកសារនេះមិនបានផ្ដល់អ្វីថ្មីនោះឡើយ។"*[9]

## ២. ការខ្វះភាពមិនលម្អៀង

[7] សៀវភៅរបស់លោក Marcel LEMONDE ទំព័រ ១៧២។ សូមមើល សំណើសុំរបស់លោក នួន ជា ឧបសម្ព័ន្ធ ឯកសារ **E189/3/1/7.3**.

[8] សំណើសុំរបស់ លោក នួន ជា កថាខណ្ឌទី៤-៥, ១២-១៤, ១៥-១៧, ១៩-២៦, ៣០ និងឧបសម្ព័ន្ធ ឯកសារពី **E189/3/1/7.1** ដល់ **E189/3/1/7.4**.

[9] សៀវភៅរបស់លោក Marcel LEMONDE ទំព័រ ៥២-៥៣។ សូមមើល ការស្នើសុំរបស់លោក នួន ជា ឧបសម្ព័ន្ធ ឯកសារ **E189/3/1/7.2**.

១២. នៅក្នុងស្នាដៃរបស់លោក លោកអតីតចៅក្រមស៊ើបអង្កេត បានបង្ហាញពីរបៀបយល់ឃើញរបស់លោកផ្ទាល់ទៅលើអង្គហេតុ ដែលស្ថិតនៅជុំវិញបណ្តឹងជិតចិត្តប្រឆាំងនឹងរូបលោករបស់ក្រុមមេធាវីការពារក្តី ដោយមូលហេតុភាពលម្អៀង។[10] បណ្តឹងទាំងនោះផ្អែកលើសេចក្តីប្រកាសរបស់អតីតសហការីរបស់លោក LEMONDE ដែលថា លោកបានប្រាប់ដល់ក្រុមការងាររបស់លោកថា លោកចង់រកភស្តុតាងដាក់បន្ទុក ច្រើនជាងភស្តុតាងដោះបន្ទុក។[11]

១៣. វាជារឿងគួរឲ្យចាប់អារម្មណ៍ នៅពេលយើងឃើញថា ខណៈដែលលោក LEMONDE ការពារខ្លួនពីភាពមានលម្អៀង ក៏ចោទក្រុមមេធាវីការពារក្តីថា បានដឹកនាំ "*អំពើមួយក្នុងបំណងរារាំងលោកមិនឲ្យបំពេញការងារ*" ដោយឥតយល់ថាក្រុមមេធាវីការពារក្តី គ្រាន់តែបំពេញការងាររបស់ខ្លួនតែប៉ុណ្ណោះ ៖

> *"ហេតុម្តេចក៏ក្រុមមេធាវីការពារក្តី ញុះញង់ឲ្យអតីតសហការីរបស់ខ្ញុំ ងាកមកប្រឆាំងនឹងខ្ញុំទៅវិញ ? ខ្ញុំមិនបានរៀបចំរឿងនោះឡើងឡើយ។ មានពាក្យចចាមអារាមថា សាម៉ីខ្លួននោះបានធ្វើការប្រកាសទាំងមិនប្រយ័ត្នប្រយែង នៅក្នុងភោជនីយដ្ឋានមួយកន្លែង ឮថាក្រុមមេធាវីការពារក្តីដឹងរឿងរ៉ាវនោះ ហើយក៏បង្ខំឲ្យសហការីនោះផ្តល់សក្ខីកម្ម បើពុំនោះទេនឹងត្រូវមានបញ្ហាខ្លួនឯងមិនខាន។ តើនិយាយនេះត្រឹមត្រូវឬទេ ? ខ្ញុំក៏មិនដឹងដែរ។ គ្រាន់តែថា គោលបំណងនៃអំពើនោះ គឺចង់រារាំងខ្ញុំមិនឲ្យបំពេញការងារ"។* [12]

១៤. ការចេញផ្សាយសៀវភៅរបស់លោក LEMONDE គឺជាការតស៊ូចង់ឲ្យសាក្សី TCW-383 និង TCW-31 មកបង្ហាញខ្លួននៅចំពោះមុខតុលាការ ដែលក្រុមមេធាវីការពារក្តីបានស្នើសុំតាំងពីដើមរៀងមក ហើយដែលជាកាតព្វកិច្ចនៃការស្វែងរកការពិត។

## ខ. បញ្ហាបកប្រែ

១៥. នៅពេលអានស្នាដៃរបស់លោក LEMONDE គេអាចប៉ាន់ស្មានដឹងពីផលប៉ះពាល់នៃការលំបាកដែលបង្កឡើងដោយបញ្ហាការបកប្រែ ក្នុងដំណើរការប្រព្រឹត្តទៅនៃការស៊ើបអង្កេត។ បើតាមអតីតចៅក្រមស៊ើបអង្កេត អ្នកស៊ើបអង្កេត "*បំពេញការងារនៅក្នុងលក្ខខណ្ឌដ៏លំបាក។ ចំពោះជន*

---

[10] សៀវភៅរបស់លោក Marcel LEMONDE ទំព័រ ១៨៦-១៩៣។ សូមអានឧបសម្ព័ន្ធនៃការស្នើសុំនេះ។

[11] សៀវភៅរបស់លោក Marcel LEMONDE ទំព័រ ១៨៧។ សូមអានឧបសម្ព័ន្ធនៃការស្នើសុំនេះ។

[12] សៀវភៅរបស់លោក Marcel LEMONDE ទំព័រ ១៩៣។ សូមអានឧបសម្ព័ន្ធនៃការស្នើសុំនេះ។

*ណាដែលដឹងច្បាស់ពី អ្វីដែលហៅថាការស៊ើបអង្កេតល្អ បរិបទកម្ពុជាគឺជាការលត់ដំមួយ"*[13] ជាពិសេស ដោយសារតែអ្នកស៊ើបអង្កេត *"ជួបជាអចិន្ត្រៃយ៍នូវបញ្ហាបកប្រែ"* នៅពេលស្តាប់សាក្សី។[14]

១៦. បញ្ហាទាំងនេះក៏កើតមានផងដែរ នៅក្នុងពេលប្រជុំ ក្នុងការិយាល័យចៅក្រមស៊ើបអង្កេត ៖

*"ទីបញ្ចប់ ស្ថានភាពនេះកាន់តែធ្ងន់ធ្ងរឡើង ដោយសារតែការងារសំខាន់ៗធ្វើឡើងជាភាសាអង់គ្លេស។ ដឹកនាំអង្គប្រជុំបច្ចេកទេសមួយ ដែលមានសមាជិក១៥នាក់ ដែលមានការកត់សម្គាល់ជាភាសាអង់គ្លេស តាមសំឡេងផ្សេងៗពីអ្នកដែលមកពីអូស្ត្រាលី ពីរដ្ឋតិចសាស់ ឬពីញូវហ្សេឡង់ គឺពិតជាបញ្ហាប្រឈមដ៏ពិតៗ។ ការមិនយល់ព័ត៌មានក្នុងការពិភាក្សាចំនួន ១០% គឺជាការនាំបញ្ហាដល់រូបខ្ញុំ។"*[15]

១៧. លោក LEMONDE ក៏មានបទពិសោធន៍ផងដែរថា ការបកប្រែប្រហាក់ប្រហែល *"ក៏អាចបង្កឲ្យមានអត្ថន័យផ្ទុយដែរ"*[16]។ ក្រុមមេធាវីការពារក្ដីបានលើកឡើងពីការលំបាកនេះ ជាច្រើនលើកច្រើនគ្រា នៅពេលសាក្សីផ្តល់សក្ខីកម្ម នៅចំពោះមុខអង្គជំនុំជម្រះ។ គឺជាចំណុចសំខាន់ដែលអង្គជំនុំជម្រះត្រូវគិតគូរដល់។ អង្គជំនុំជម្រះបានទទួលយកជាតឹកតាង នូវកំណត់ហេតុជាច្រើនរបស់អ្នកស៊ើបអង្កេត នៃការិយាល័យចៅក្រមស៊ើបអង្កេត។ ចំណុចនេះកាន់តែសំខាន់ណាស់ទៅទៀត ពីព្រោះថាចំពោះបញ្ហាទទួលយកសេចក្តីប្រកាសជាលាយលក្ខណ៍អក្សរនេះ ពុំមានការផ្ទៀងផ្ទាត់សោះឡើយនៅក្នុងក្របខណ្ឌនៃការចោទសួរក្នុងសវនាការ។

## គ. ការជ្រើសយុទ្ធសាស្ត្រដែលមានព្យសនកម្ម

១៨. នៅក្នុងស្នាដៃរបស់លោក លោក LEMONDE បានលើកឡើងពី "យុទ្ធសាស្ត្រ" របស់លោកក្នុងការស៊ើបសួរ ក្នុងសំណុំរឿង០០១ និង០០២។ "យុទ្ធសាស្ត្រ"នេះ មិនត្រឹមតែមានផលប៉ះពាល់ទៅលើរយៈពេលនៃការឃុំខ្លួនបណ្តោះអាសន្នរបស់លោក ខៀវ សំផន ប៉ុណ្ណោះទេ តែវាថែមទាំងប៉ះពាល់ដល់ការស្រាវជ្រាវ និងការប្រមូលភស្តុតាងនៅក្នុងសំណុំរឿង ០០២ ទៀតផង។

---

[13] សៀវភៅរបស់លោក Marcel LEMONDE ទំព័រ ១៣១។ សូមអានការស្នើសុំទី១ ឧបសម្ព័ន្ធ E280.6

[14] សៀវភៅរបស់លោក Marcel LEMONDE ទំព័រ ១៣២។ (យើងជាអ្នកគូសបន្ទាត់ពីក្រោម) សូមអានការស្នើសុំទី១ ឧបសម្ព័ន្ធ E280.7

[15] សៀវភៅរបស់លោក Marcel LEMONDE ទំព័រ ១៣២-១៣៣។ សូមអានការស្នើសុំទី១ ឧបសម្ព័ន្ធ E280.7

[16] សៀវភៅរបស់លោក Marcel LEMONDE ទំព័រ ៣៤។ សូមអានឧបសម្ព័ន្ធនៃការស្នើសុំនេះ។

១៩. ពីដំបូង គេដឹងថាហេតុអ្វីបានជា ចាប់ពីខែកក្កដា ឆ្នាំ២០០៧មក អតីតសហចៅក្រមស៊ើបអង្កេត មានបំណងផ្តល់អាទិភាពដល់ករណីលោក ឌុច។ បន្ទាប់ពីបានយល់ដឹង ពីដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទី១ របស់សហព្រះរាជអាជ្ញាដែលមានចំនួន ១៤០០០ទំព័រ ដែលចោទប្រកាន់លើមនុស្សប្រាំរូប (ឌុច និងអតីតមេដឹកនាំនៃរបបនោះ) លោកក៏បានសរសេរថា ៖

> *"ភ្លាមនោះ ខ្ញុំមានការជឿជាក់ថា គេមិនអាចចាត់ការរឿងនេះ តាមបែបនោះឡើយ។ គេត្រូវចែកបញ្ហាជាប្រភេទ បើពុំនោះទេ យើងមិនអាចធ្វើអ្វីបានឡើយ។ ខ្ញុំបាននិយាយបញ្ចុះបញ្ចូល លោក យូ ប៊ុនឡេង ថា គប្បីចាប់ផ្តើមរឿងឌុចមុនគេ។ ដំបូង ដោយហេតុថា បញ្ហារឿងការឃុំខ្លួនគាត់យូរ មិនអាចឱ្យយើងនៅអែរអង់បានឡើយ។ គាត់ត្រូវគេចាប់ខ្លួន នៅឆ្នាំ១៩៩៩ ហើយចាប់ពីពេលនោះមក គាត់ត្រូវគេឃុំ "បណ្តោះអាសន្ន" ក្រោមការគ្រប់គ្រងពីតុលាការយោធា។ ម៉្យាងវិញទៀត សំណុំរឿងរបស់គាត់មានលក្ខណៈងាយ ហើយរៀបរយក្រុមការងារយើងខ្ញុំ និងកិច្ចសហការរបស់យើង។ ចុងបញ្ចប់ ការបំបែកសំណុំរឿងតូចៗនេះ មានអត្ថប្រយោជន៍ក្នុងការជម្រុញឱ្យតុលាការបើកសវនាការជំនុំជម្រះ ទៅតាមថិរវេលាមួយសមស្រប ដែលជាអ្វីដែលមនុស្សគ្រប់គ្នារង់ចាំយ៉ាងអន្ទះសា។ ចម្លែកណាស់ សហព្រះរាជអាជ្ញា មិនយល់ស្របតាមដំណោះស្រាយនេះឡើយ។ សហព្រះរាជអាជ្ញាចង់ធ្វើជា "សវនាការដ៏ធំ" មួយ ដែលយើងយល់ថា មិនមានភាពប្រាកដនិយមឡើយ នៅក្នុងថិរវេលាខ្លីបែបនេះ។ យើងបានសម្រេចចិត្តមិនគិតដល់ចំណុចទាំងនោះឡើយ ហើយក៏បង្គាប់ឱ្យមានការបំបែកសំណុំរឿង"*។[17]

២០. ចាប់ពីខែ កក្កដា ឆ្នាំ ២០០៧ មក លោក LEMONDE បានដឹងយ៉ាងច្បាស់ថា មានឱកាសតិចតួចណាស់ក្នុងការចាប់ផ្តើមជំនុំជម្រះរឿងក្តីធំមួយ ក្នុងរយៈពេលសមស្រប ហើយលោកក៏ដឹងដែរថា នៅពេលដែលលោកបានផ្តល់អាទិភាពទៅលើសំណុំរឿងទីមួយដែលមានទំហំតូច (និង "សាមញ្ញ") លោកត្រូវដកថយចំពោះទស្សនវិស័យនៃការបើកទ្វាទូលាយ គឺដកថយចំពោះច្រកឆ្ពោះទៅរកសំណុំរឿងទំហំធំ នៅក្នុងថិរវេលាដ៏សមស្របមួយ។

២១. ដូច្នេះ ហេតុអ្វីបានជាត្រូវបង្គាប់ឱ្យឃុំខ្លួនអតីតមេដឹកនាំទាំងបួនរូបនេះ ក្រោយពីការបំបែកសំណុំរឿងបានបន្តិច? សៀវភៅរបស់លោក LEMONDE បង្ហើបឱ្យដឹងថាសេចក្តីសម្រេចនេះមានចរិតនយោបាយច្រើនជាងចរិតគតិយុត្តិ។

---

[17] សៀវភៅរបស់លោក LEMONDE ទំព័រ ៤២-៤៣។ សូមអានការស្នើសុំទី១ ឧបសម្ព័ន្ធ E280.1

២២. មូលហេតុ គឺថាបន្ទាប់ពីការតែងតាំង លោក យូ ប៊ុនឡេង ដែលជាសមភាគីជាតិរបស់ខ្លួន ទៅកាន់សាលាឧទ្ធរណ៍ (ដែលលោក LEMONDE មានបំណងចង់រារាំង) កាលពីខែ សីហា ឆ្នាំ ២០០៧ រួចមក លោក LEMONDE បានប្រាប់ថាលោកនឹងធ្វើការចាប់ខ្លួនជនសង្ស័យនាពេលដ៏ខ្លីខាងមុខ៖

> *"ពាក់ព័ន្ធនឹងការតែងតាំងលោក យូ ប៊ុនឡេង ខ្ញុំរកមិនឃើញថាមានវិធីណាមួយដែលអាចចេញផុតពីការជាប់គាំងនេះបានទេ។ តើត្រូវលាលែងពីតំណែង ប្រសិនបើរដ្ឋាភិបាលមានបំណងវិលទៅរកស្ថានភាពដើម? ជាក់ស្តែង ខ្ញុំបានដឹងយ៉ាងច្បាស់ថា នេះមិនមែនជាជម្រើសដ៏ពិតប្រាកដនោះទេ (...) ដូច្នេះ ខ្ញុំត្រូវប្រើមធ្យោបាយផ្សេងទៀត និងត្រូវបង្ហាញថា ការរក្សាទុកលោក យូ ប៊ុនឡេង ពិតជាមានសារៈសំខាន់ណាស់។ ខ្ញុំបានសម្រេចចិត្តប្រកាសប្រាប់លោកឯកអគ្គរដ្ឋទូតបារាំងថា "ការស៊ើបអង្កេតដែលមានលក្ខណៈធំធ្ងន់នឹងត្រូវធ្វើឡើងក្នុងរយៈពេលដ៏ខ្លីខាងមុខ" ហើយដែលការប្រកាសបែបនេះ គឺជារបៀបមួយដើម្បីបង្ហាញទៅពួកគេទាំងអស់គ្នាថា ការចាប់ផ្តើមនៅក្នុងលក្ខខណ្ឌបែបនេះគឺជាការធ្វើឱ្យអន្តរាយ"។ ជាការពិតណាស់ គឺខ្ញុំបាននឹកទៅដល់ការចាប់ខ្លួននាពេលប៉ុន្មានសប្តាហ៍ខាងមុខ។ (...)"*[18]។

២៣. តែមិនមែនបែបនោះឡើយ ចាប់តាំងពីពេលចាប់ខ្លួនជនសង្ស័យទាំងបួនរូបនេះការស៊ើបអង្កេតនៅក្នុងសំណុំរឿង ០០២ មិនត្រូវបានធ្វើឡើងប្រកបដោយការយកចិត្តទុកដាក់ទេ។ ការពិតគឺវាផ្ទុយស្រឡះ៖

> *"ការងារអាទិភាពគឺត្រូវបញ្ចប់សំណុំរឿងរបស់ ឌុច មុននឹងចាប់ផ្តើមធ្វើសំណុំរឿង ០០២ របស់អតីតមេដឹកនាំរបបកម្ពុជាប្រជាធិបតេយ្យទាំងបួនរូប។ សំណុំរឿងទាំងពីរនេះអាចត្រូវលើកយកមកពិនិត្យ ក្នុងលក្ខណៈបន្តបន្ទាប់គ្នាតែប៉ុណ្ណោះ"*[19]។

២៤. ប៉ុន្តែ ទោះបីជាមាន "*យុទ្ធសាស្ត្រតែមួយគត់សម្រាប់សំណុំរឿង ០០១៖ ការឈានដល់ដំណាក់កាលជំនុំជម្រះឱ្យបានលឿនតាមដែលអាចធ្វើទៅបាន*" ក៏ដោយ ក៏មិនមែនមានន័យថាត្រូវចាប់ផ្តើមសំណុំរឿង ០០២ ឱ្យបានឆាប់រហ័សនោះដែរ។ យើងត្រូវបំពេញចិត្តសង្គមស៊ីវិល ដែលអន្ទះសារង់ចាំមើលសំណុំរឿងរបស់ ឌុច ចាប់ផ្តើម ព្រោះ "*សាធារណជនមានអារម្មណ៍ថាពុំមានឃើញអ្វីកើតឡើងសោះ*"[20]។

---

[18] សៀវភៅរបស់លោក Marcel LEMONDE ទំព័រ ៥១-៥២។

[19] សៀវភៅរបស់លោក Marcel LEMONDE ទំព័រ ១៣១។ សូមអានការស្នើសុំទី១ ឧបសម្ព័ន្ធ E280.6

[20] សៀវភៅរបស់លោក Marcel LEMONDE ទំព័រ ១៤៤។ សូមអានការស្នើសុំទី១ ឧបសម្ព័ន្ធ E280.8

២៥. សារៈសំខាន់ក្នុងការឈានទៅដល់គោលដៅនេះ លេចឡើងតាមរយៈការអានស្នាដៃរបស់អតីតសហចៅក្រមស៊ើបអង្កេត ដែលបានបង្ហាញពីការខកចិត្តរបស់លោក បណ្តាលមកពីការលំបាក និងការយឺតយ៉ាវបង្កឡើងដោយសហព្រះរាជអាជ្ញា[21]។

២៦. លោក LEMONDE បានមានប្រសាសន៍ថា គឺទើបតែនៅពេលដែលការស៊ើបអង្កេតសំណុំរឿង ០០១ ត្រូវបានបញ្ចប់ទៅហើយទេ ដែលលោកបានយល់កាន់តែច្បាស់ពីទំហំនៃសំណុំរឿង ០០២៖

> *"នៅពេលដែលយើងកំពុងធ្វើការក្នុងសំណុំរឿងរបស់ ឌុច អ្វីៗមានភាពងាយស្រួល៖ យុទ្ធសាស្ត្រគឺផ្តោតទៅលើការកម្រិតនៅត្រឹមអ្វីដែលមានសារៈប្រយោជន៍ និងឈានឱ្យដល់គោលដៅឱ្យបានលឿនតាមដែលអាចធ្វើទៅបាន។ ថ្ងៃដែលសំណុំរឿងនេះត្រូវបានបិទបញ្ចប់ ខ្ញុំបានចាត់ការសំណុំរឿងដ៏ធំសំបើមដែលកំពុងរង់ចាំយើង"*[22]។

២៧. ជាមួយនឹងសំណុំរឿងដ៏"ធំសំបើម" ដែលកំពុងរង់ចាំពួកគេនោះ គឺមានជនត្រូវចោទទាំងបួនរូបដែលមានវ័យចំណាស់ និងជាប់ឃុំឃាំង កំពុងរង់ចាំ។

២៨. បើទោះជាពេលវេលាដែលជនជាប់ចោទនៅក្នុងសំណុំរឿង ០០២ ត្រូវបានឃុំខ្លួនបណ្តោះអាសន្នយ៉ាងយូរបែបនេះទៅហើយក្តី ក៏"យុទ្ធសាស្ត្រ"នៃអតីចៅក្រមស៊ើបអង្កេត គឺខុសគ្នាទាំងស្រុងពី យុទ្ធសាស្ត្រនៅក្នុងសំណុំរឿង ០០១។ គឺមិនមែនពន្លឿនដំណើរការឱ្យបានឆាប់រហ័សបំផុតនោះទេ តែគ្រាន់តែបញ្ចប់ កុំឱ្យហួសថិរវេលាកំណត់អតិបរមានៃការឃុំខ្លួនបណ្តោះអាសន្នតែប៉ុណ្ណោះ ៖

> *"ក្នុងពេលនោះ នៅការិយាល័យចៅក្រមស៊ើបអង្កេត យើងខំប្រឹងធ្វើយ៉ាងណាបញ្ចប់ការស៊ើបសួរនៅក្នុងសំណុំរឿង ០០២ ឱ្យបានទាន់ពេលវេលា (...) ។ ទីបញ្ចប់ គឺនៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០ ទើបសម្រេចបានតាមគោលដៅ។ (...) ដល់ពេលវេលាហើយ ៖ ការឃុំខ្លួនលោក នួន ជា បណ្តោះអាសន្ន នឹងផុតកំណត់នៅបីថ្ងៃខាងមុខនេះហើយ"* ។[23]

---

[21] សៀវភៅរបស់លោក Marcel LEMONDE ទំព័រ ១៤៥-១៤៩។ សូមអានការស្នើសុំទី១ ឧបសម្ព័ន្ធ E280.9

[22] សៀវភៅរបស់លោក Marcel LEMONDE ទំព័រ ១៣២។ សូមអានការស្នើសុំទី១ ឧបសម្ព័ន្ធ E280.7

[23] សៀវភៅរបស់លោក LEMONDE ទំព័រ ២០១ ។ សូមអានការស្នើសុំទី១ ឧបសម្ព័ន្ធ E280.11

២៩. ករណីនេះពុំមែនជាការកម្រិតត្រឹមតែទៅលើខ្លឹមសារទៀតឡើយ ប៉ុន្តែគឺជាការបន្សល់ទុកនូវកេរ្តិ៍ដំណែលសម្រាប់ពេលអនាគត៖

> *"សូម្បីតែនៅក្នុងដំណាក់កាលនេះ គេមិនអាចច្រានចោលទាំងស្រុងនូវសម្មតិកម្មដែលថារឿងក្តី នេះមិនដែលកើតមានឡើងទាល់តែសោះ៖ ដោយមើលឃើញអំពីភាពមិនឋិតថេរនៃតុលាការនេះ ព្រមទាំងអាយុចាស់ជរានៃជនជាប់ចោទ អនាគតភាពមានភាពមិនច្បាស់លាស់។ ជាមួយគ្នានេះដែរ យើងយល់ឃើញថា វាជារឿងមួយសំខាន់ក្នុងការតាក់តែងដីកាដំណោះស្រាយ គឺធ្វើហាក់ដូចជាការជម្រះក្តីលើពួកខ្មែរក្រហមពុំបានកើតឡើងដូច្នោះដែរ (...) ដីកាដំណោះស្រាយបានបង្ហាញអំពីទិដ្ឋភាពផ្លូវច្បាប់ ប្រវត្តិសាស្ត្រ និងព្រឹត្តិការណ៍ជាក់ស្តែងនានា ដែលព័ត៌មានអស់ទាំងនោះ ពុំមែនមានលក្ខណៈចាំបាច់ដាច់ខាតនោះទេ ប៉ុន្តែវាមានសារៈសំខាន់ចំពោះយើង ក្នុងករណីដែលសេចក្តីសម្រេចរបស់យើងនៅតែជាកេរ្តិ៍ដំណែលដែលបន្សល់ទុកដោយតុលាការនេះ ដើម្បីឆ្លុះបញ្ចាំងអំពីព្រឹត្តិការណ៍ដែលបានកើតឡើងនៅក្នុងប្រទេសកម្ពុជាចន្លោះពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ១៩៧៥ រហូតដល់ថ្ងៃទី ៦ ខែ មករា ឆ្នាំ ១៩៧៩។"*[24]។

៣០. នៅក្នុងលក្ខខណ្ឌទាំងនេះហើយ ដែលលោក ខៀវ សំផន ត្រូវបានគេឃុំខ្លួនអស់រយៈពេលបីឆ្នាំ។ ទង្វើនេះសបង្ហាញឲ្យឃើញអំពីកំហុសយ៉ាងជាក់ច្បាស់ក្នុងការដែលមិនបាន "បំពេញការងារដោយយកចិត្តទុកដាក់" ដូចដែលបានតម្រូវដោយបទដ្ឋានអន្តរជាតិពាក់ព័ន្ធនឹងការដកហូតសិទ្ធិសេរីភាពបុគ្គលដែលត្រូវបានគេសន្មតថាគ្មានទោសនោះ[25]។

៣១. ការស៊ើបអង្កេតនៃសំណុំរឿង០០២ ត្រូវបានធ្វើឡើង នៅក្នុងលក្ខខណ្ឌបែបនេះ គឺថា ការស្រាវជ្រាវ និងការប្រមូលភស្តុតាងដែលត្រូវបានធ្វើឡើងរយៈពេលប្រហែលពីរឆ្នាំ ទៅតាមទិសដៅមួយដែលមានលក្ខណៈគតិយុត្តិ តិចជាងប្រវត្តិសាស្ត្រ។ ដូច្នេះ ទំនងជាមុននឹងបញ្ចប់ឲ្យបានឆាប់ ការស៊ើបអង្កេតគិតទៅលើបរិមាណ ច្រើនជាងគុណភាពនៃភស្តុតាង ដែលជាការសមស្រប គេគួរតែចោទសួរភាពពាក់ព័ន្ធនៃភស្តុតាងមួយចំនួនធំ។

---

[24] សៀវភៅរបស់លោក Marcel LEMONDE ទំព័រ ២០២។ សូមអានការស្នើសុំទី១ ឧបសម្ព័ន្ធ E280.12

[25] សូមមើលជាអាទិ៍ យុត្តិសាស្ត្ររបស់តុលាការសិទ្ធិមនុស្សអឺរ៉ុប ឧទាហរណ៍ក្នុង៖ រឿងក្តី *Labita ទល់នឹងប្រទេសអ៊ីតាលី* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការសិទ្ធិមនុស្សអឺរ៉ុប ចុះថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០០០ កថាខណ្ឌ ១៥៣, រឿងក្តី *Velichko ទល់នឹងប្រទេសរុស្ស៊ី* សាលដីកា តុលាការសិទ្ធិមនុស្សអឺរ៉ុប ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០១៣ កថាខណ្ឌ ៨៥។

## II. ការវាយតម្លៃភស្តុតាងដែលប្រមូលបានក្នុងពេលស៊ើបសួរ

៣២. ការវាយតម្លៃរបស់លោកអតីតសហចៅក្រមស៊ើបអង្កេត ទៅលើភស្តុតាង ដែលលោកប្រមូលបាន អាចឲ្យគេវាយតម្លៃនៃភាពគួរឲ្យជឿទុកចិត្តបានរបស់វា។ ក្នុងស្នាដៃលោក លោក LEMONDE បានផ្តល់យោបល់លោក ទាក់ទងនឹងករណីលោក ខៀវ សំផន ព្រមទាំងទៅលើភស្តុតាងដែលផ្តល់ដោយសាក្សីខ្លះៗ និងធាតុផ្សេងៗទៀត។

### **ក. ករណី** លោក ខៀវ សំផន

៣៣. នៅក្នុងសៀវភៅរបស់គាត់ លោក LEMONDE បានបង្ហាញអំពីភាពរួញរារបស់គាត់កាលពី សរទរដូវនាឆ្នាំ ២០០៧ ក្នុងការសម្រេចឃុំខ្លួនជនសង្ស័យទាំងបួននាក់ក្នុងសំណុំរឿង ០០២ បណ្តោះអាសន្ន ឬដាក់នៅក្រោមការត្រួតពិនិត្យរបស់តុលាការ នាសរទរដូវឆ្នាំ ២០០៧ នោះ។ លោកក៏បានបញ្ជាក់ផងដែរថា កិច្ចពិភាក្សានានាពាក់ព័ន្ធនឹងបញ្ហានេះនៅក្នុងរង្វង់ក្រុមសហចៅក្រមស៊ើបអង្កេតត្រូវបាន "ធ្វើឲ្យលេចចេញជារូបរាង"។

៣៤. ស្នាដៃនេះបង្ហាញថា មានការរារែកយ៉ាងខ្លាំងចំពោះករណី អ្នកស្រី អៀង ធីរិទ្ធ និងលោក ខៀវ សំផន។

៣៥. ក្រោយពីបានលើកអំពីករណីរបស់លោក នួន ជា និង លោក អៀង សារី មក អតីតសហចៅក្រមស៊ើបអង្កេត បានត្រលប់មកករណីរបស់លោកស្រី អៀង ធីរិទ្ធ វិញ៖

> *"នៅលើអង្គសេចក្តី ចំពោះករណីលោក អៀង សារី ប្រសិនណាជាបន្ទុកនៃការចោទប្រកាន់មាន លក្ខណៈជាក់ច្បាស់ និងធ្ងន់ធ្ងរចាប់ពីពេលនេះតទៅមុខ នោះសម្រាប់ករណីលោកស្រី អៀង ធីរិទ្ធ វិញ ធាតុផ្សំនៃភស្តុតាងដែលយើងមាន រឹតតែមានលក្ខណៈជាក់ច្បាស់ និងធ្ងន់ធ្ងរជាងនេះទៅ ទៀត។ ដោយបញ្ចប់តាមរយៈការសម្រេចតម្កល់រឿងទុកមិនចាត់ការ បន្ទាប់ពីបានឃុំខ្លួនបណ្តោះ អាសន្នអស់រយៈពេលដ៏យូរ គឺជារឿងមួយដែលទាល់ច្រក។ បន្ទាប់ពីបានពិភាក្សាអស់រយៈពេលដ៏ យូរលើបញ្ហានេះ ចៅក្រម យូ ប៊ុនឡេង និងរូបខ្ញុំផ្ទាល់ ទីបំផុត បានសម្រេចធ្វើការឃុំខ្លួនលោកស្រី អៀង ធីរិទ្ធ ផងដែរ (កំណត់សម្គាល់ជើងទំព័រដែលយោងលើដីកាសម្រេចឃុំខ្លួន ដែលអាចរកបាន នៅ លើគេហទំព័រ )។*
>
> *(...)*
>
> *នៅទីបញ្ចប់ ធាតុផ្សំនៃភស្តុតាងដែលទទួលបាននៅក្នុងអំឡុងពេលស៊ើបសួរគឺថា បញ្ហានៃការ សម្រេចតម្កល់រឿងទុកមិនចាត់ការ មិនបានចោទឡើងទេនៅពេលដែលមានការចុះហត្ថលេខាលើ ដីកាដំណោះស្រាយនោះ ។ បីឆ្នាំក្រោយមក៖ មានលេចឡើងនូវភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់ដែល មិនអាចប្រកែកបាន ពាក់ព័ន្ធនឹង*

*ជនជាប់ចោទ អៀង ធីរិទ្ធ ដើម្បីឱ្យជនជាប់ចោទរូបនេះអាចត្រូវ បាននាំយកមកកាត់ទោសវិញ* (កំណត់សម្គាល់ជើងទំព័រដែលបានយោងលើកថាខណ្ឌ ១២០១ ដល់ កថាខណ្ឌ ១២៩៨ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ)"[26]។

៣៦. នៅក្នុងសៀវភៅនោះ ចំណុចខាងក្រោមៗមកទៀត ពាក់ព័ន្ធនឹងលោក ខៀវ សំផន លោក LEMONDE មិនបានធ្វើការបកស្រាយស៊ីជម្រៅទេ ប៉ុន្តែបានធ្វើដូចគ្នា ដោយយោងទៅលើដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន និងលើកថាខណ្ឌ ១១២៦ ដល់កថាខណ្ឌ ១២០០ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ[27]។

៣៧. នៅក្នុងករណីទាំងពីរនេះ ការណ៍ដែលអតីតសហចៅក្រមស៊ើបអង្កេតរូបនេះត្រូវការយោងទៅលើដីកាបញ្ជូនរឿងទៅជំនុំជម្រះ (ឯកសារនេះបានបញ្ចប់កិច្ចស៊ើបសួរ ខណៈដែលការសម្រេចឃុំខ្លួនបណ្ដោះអាសន្នត្រូវបានធ្វើតាំងតែពីមុនពេលដែលមានកិច្ចស៊ើបសួរម្ល៉េះ) បានបង្ហាញអំពីភាពទន់ខ្សោយក្នុងការបង្ហាញនូវហេតុផលសមស្របក្នុងការសម្រេចធ្វើការឃុំខ្លួនបណ្ដោះអាសន្នលើជនសង្ស័យទាំងពីររូបនោះ។

៣៨. ដោយឡែក ផ្អែកលើចក្ខុវិស័យច្បាប់ ភាពរឹងមាំខាងហេតុផលត្រូវការជាចាំបាច់ដើម្បីសម្រេចឱ្យមានការឃុំខ្លួនបណ្ដោះអាសន្ន។ បើផ្អែកតាមយុត្តិសាស្ត្ររបស់តុលាការកំពូល៖

> "*វិធាន ៦៣ (៣) នៃវិធានផ្ទៃក្នុងចែងថា សហចៅក្រមស៊ើបអង្កេតអាចបង្គាប់ឱ្យធ្វើការឃុំខ្លួន បាន នៅពេលដែលលក្ខខណ្ឌពីរត្រូវបានបំពេញ។ លក្ខខណ្ឌទីមួយនៃវិធាន ៦៣ (៣) (ក) គឺ ជាលក្ខខណ្ឌនៃមូលហេតុដែលត្រូវបានរកឃើញ និងជឿជាក់យ៉ាងច្បាស់ថា ជននោះធ្លាប់បានប្រព្រឹត្តបទល្មើសមួយដែលត្រូវបានចោទប្រកាន់។ នេះគឺជាវិសាលភាពទូទៅមួយដែលត្រូវតែបង្ហាញដោយវិជ្ជមាន ដើម្បីធ្វើការពិចារណាលើលក្ខខណ្ឌជាក់លាក់ណាមួយសម្រាប់ការឃុំខ្លួន តាមចំណុច (ខ)។ លក្ខខណ្ឌទីពីរគឺថា យ៉ាងហោចណាស់ត្រូវមានមូលដ្ឋានមួយក្នុងចំណោម មូលដ្ឋានទាំងប្រាំដែលបានរៀបរាប់នៅក្នុងវិធាន ៦៣ (៣) (ខ) នៃវិធានផ្ទៃក្នុង*"[28]។

---

[26] សៀវភៅរបស់លោក Marcel LEMONDE ទំព័រ ៧៩-៨០។ សូមអានការស្នើសុំទី១ ឧបសម្ព័ន្ធ E280.3

[27] សៀវភៅរបស់លោក Marcel LEMONDE ទំព័រ ៨៦។ សូមអានការស្នើសុំទី១ ឧបសម្ព័ន្ធ E280.4

[28] សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន ស្ដីពីសំណើសុំដោះលែងជាបន្ទាន់ ចុះថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០១១ ឯកសារ **E50/3/1/4** កថាខណ្ឌ ៣៩ (យើងគូសបន្ទាត់ពីក្រោម)។

៣៩. ភាពទន់ខ្សោយ ឬកង្វះខាតនូវហេតុផលរឹងមាំនេះ ក៏កើតមានឡើងផងដែរ នៅខណៈដែលអតីត សហចៅក្រមស៊ើបអង្កេតរូបនោះបានពិចារណាអំពីករណីរបស់លោក ខៀវ សំផន បន្ទាប់ពីលោកបានចេញសេចក្ដីសម្រេចដំបូងក្នុងការឃុំខ្លួនបណ្ដោះអាសន្នលើជនត្រូវចោទរូបនោះ។

៤០. តាមពិតទៅ ពីព្រោះថា បើតាមលោក LEMONDE មេធាវីដែលមានវត្តមាននាពេលលោកខៀវ សំផន ចូលបង្ហាញខ្លួនលើកដំបូងនៅតុលាការ "អាចមានពាក្យពេចន៍និយាយ មានបន្ទុកដែលត្រូវពិភាក្សាស្ដីពីអង្គសេចក្ដី ព្រោះថាសំណុំរឿងរបស់អតីតប្រធានរដ្ឋ មិនមែនគួរធ្ងន់ធ្ងរ ដូចអ្នកប្អូនរូបផ្សេងទៀតឡើយ"។[29]

៤១. នៅក្នុងសៀវភៅរបស់ខ្លួននោះផងដែរ អតីតសហចៅក្រមស៊ើបអង្កេតរូបនោះក៏បានរំលឹកអំពីករណីដែលពាក់ព័ន្ធនឹងលោក ខៀវ សំផន ដូចខាងក្រោម៖

> *"ករណីរបស់លោក ខៀវ សំផន មានលក្ខណៈស្មុគស្មាញជាងនេះ។ តួនាទីរបស់គាត់គឺតំណាង ឲ្យរបបកម្ពុជាប្រជាធិបតេយ្យជាសាធារណៈ ពោលគឺជាឋានៈដែលគួរឲ្យគោរពនៃរបបនោះ (...) គាត់តែងតែធ្វើការការពារខ្លួនគាត់ដោយពោលថា "ចូរបង្ហាញភស្តុតាងដែលបញ្ជាក់ថាខ្ញុំបានដឹង"។ ពិតប្រាកដហើយ គាត់ពុំបានបន្សល់ទុកនូវស្លាកស្នាមអ្វីឡើយ។ គេពុំមានភស្តុតាងណាមួយដែល បង្ហាញថា គាត់បានចេញសេចក្ដីសម្រេចច្បាស់លាស់ក្នុងការចាប់ខ្លួនមនុស្ស ឬសម្លាប់មនុស្សនោះ ឡើយ។ មិនតែប៉ុណ្ណោះ ឈ្មោះរបស់គាត់ក៏ពុំដែលត្រូវបានឃើញសរសេរនៅលើចម្លើយសារភាព របស់អ្នកទោស ដែលសម្គាល់ថាជាអ្នកដែលទទួលចម្លើយសារភាពនោះដែរ ផ្ទុយពីករណីរបស់ អៀង ធីរិទ្ធ ជាឧទាហរណ៍។ ដោយឡែក ផ្អែកលើសុន្ទរកថានានា និងកាន់កាប់តួនាទីជា សាធារណៈរបស់គាត់នាសម័យនោះ ព្រមទាំងការចូលរួមជាប្រចាំរបស់គាត់ក្នុងកិច្ចប្រជុំគណៈ អចិន្ត្រៃយ៍ និងការប្រាស័យទាក់ទាក់ជិតស្និទ្ធរបស់គាត់ជាមួយមេដឹកនាំដទៃទៀត វាជារឿងដែលមិនអាចទៅរួចទាល់តែសោះដែលថា ខៀវ សំផន ពុំបានដឹងអំពីការសម្លាប់ និងការដាក់ប្រជាជន នៅទូទាំងប្រទេសក្រោមរបបទាសភាពដ៏សែនព្រៃផ្សៃនោះ។ នៅខណៈដែលគាត់បានដឹងអំពីការ ពិតអស់ទាំងនេះ ហើយទន្ទឹមនោះ គាត់បែរជាថ្លែងនូវសុន្ទរកថាដែលមានលក្ខណៈជាការលើក សរសើរសមិទ្ធិផលនៃរបបនោះ គាត់អាចត្រូវបានចោទប្រកាន់ថាជាជនសមគំនិត។ ជាសរុបមក តើ ខៀវ សំផន ពុំមែនកំពុងតែឆ្លើយយករួចខ្លួនទេឬ? ប្រសិនណាជាគាត់អះអាងថា គាត់ពុំបានប៉ង ប្រាថ្នាអ្វីក្រៅតែអំពីភាពសុខសាន្តរបស់ប្រជាជន ហើយគាត់ទើបតែបានដឹងអំពីវិនាសកម្មដែល ប្រជាជនបានទទួលរង គឺនៅពេលដែលព្រឹត្តិការណ៍បានបញ្ចប់ទៅអស់រយៈកាលដ៏យូរមកហើយ គឺប្រហែលជាដោយសារគាត់ពុំអាចទទួលស្គាល់ថា ជាក់ស្ដែងគាត់មានការភ័យខ្លាចតក់ស្លុត ហើយគ្មានគិតអ្វីក្រៅតែអំពីការរកច្រកចេញនោះ"*[30]។

---

[29] សៀវភៅរបស់លោក LEMONDE ទំព័រទី៨៩។ សូមអានការស្នើសុំទី១ ឧបសម្ព័ន្ធ E280.5

[30] សៀវភៅរបស់លោក Marcel LEMONDE ទំព័រ ១៥៨-១៥៩។ សូមអានការស្នើសុំទី១ ឧបសម្ព័ន្ធ E280.10

៤២. ជាសរុបមក មេធាវីការពារក្តីចង់បង្ហាញថា ចៅក្រមដែលបានចំណាយពេលវេលារាប់ខែក្នុងការស៊ើបអង្កេតលើសំណុំរឿងរបស់លោក ខៀវ សំផន និងប្រមូលភ័ស្តុតាងនានា មិនអាចធ្វើអ្វីផ្សេងទៀតបានក្រៅតែអំពីធ្វើការសន្មត់។

៤៣. ដោយឡែក វាជារឿងមួយដែលគួរឲ្យឆ្ងល់សចិត្ត ក្នុងការដែលសន្និដ្ឋានថា ភ័ស្តុតាងដាក់បន្ទុកដែលលោក LEMONDE បានលើកឡើងនៅក្នុងដីកាដំណោះស្រាយរបស់ខ្លួន ប្រឆាំងនឹងលោក ខៀវ សំផន មានលក្ខណៈចាកឆ្ងាយអំពីបទសមគំនិត។ ក្រៅអំពីនោះ រាល់ភ័ស្តុតាងដាក់បន្ទុកទាំងឡាយប្រឆាំងនឹងលោក ខៀវ សំផន ក្នុងនាមជាចារីដែដល់ គឺជាផ្នែកនៃ "*បទបង្ហាញអំពីទិដ្ឋភាពច្បាប់ប្រវត្តិសាស្ត្រ និងព្រឹត្តិការណ៍ជាក់ស្តែងនានា ដែលព័ត៌មានអស់ទាំងនោះពុំមែនមានលក្ខណៈចាំបាច់ដាច់ខាតនោះទេ ប៉ុន្តែវាមានសារៈសំខាន់ចំពោះគាត់ ក្នុងករណីដែលដីកាដំណោះស្រាយនៅតែជាកេរ្តិ៍ដំណែលតែមួយគត់ដែលបន្សល់ទុកដោយតុលាការនេះ* "? ក្រោយពីបានឃើញសំណេររបស់លោក LEMONDE ដូច្នេះ វាហាក់ដូចជាមានលក្ខណៈស្របច្បាប់ក្នុងការចោទជាសំណួរមកលើខ្លួនឯង។

ខ. <u>ការវាយតម្លៃនៃសក្ខីកម្មសាក្សីខ្លះ</u>

៤៤. លោកអតីតសហចៅក្រមស៊ើបអង្កេតក៏បានធ្វើការវាយតម្លៃផងដែរ ទៅលើសាក្សីខ្លះ ដែលលោកបានស្តាប់ (ហើយដែលក្រោយមកបានផ្តល់សក្ខីកម្មនៅក្នុងសវនាការ)។

៤៥. ជាឧទាហរណ៍ លោក LEMONDE បានសរសេរអំពី កាំងហ្កេកអ៊ាវ ហៅឌុច ដែលបានដឹងលឺពីភស្តុតាងថ្មីៗបណ្តើរៗក្នុងពេលស៊ើបអង្កេតក្នុងរឿងក្តីរបស់គាត់ ៖

> *"ការលំបាកនោះគឺស្ថិតនៅត្រង់ថា តើត្រូវគន់គូរមើលថាតើចាប់ពីពេលណាទៅ ទើបគេចេញផុតពីសក្ខីកម្មពិត ផ្អែកលើបទពិសោធន៍ផ្ទាល់ខ្លួនគាត់ ដើម្បីចូលទៅក្នុងផ្នែកអត្ថាធិប្បាយ នៃអ្វីដែលគាត់បានស្វែងយល់ឃើញ ដោយអានសំណុំរឿងគាត់ក្នុងអឡុងពេលប៉ុន្មានខែចុងក្រោយនោះ។ ពិតណាស់ រឿងនេះវាកាន់តែគួរឲ្យចាប់អារម្មណ៍ ព្រោះគាត់យល់រឿងកាន់តែច្បាស់ឡើងៗ ប៉ុន្តែបញ្ហានោះ គឺថាគាត់មានទំនោរកែប្រែសាច់រឿងជាថ្មី ច្រើនជាងរៀបរាប់ពីអ្វីដែលគាត់បានដឹងកាលពីសម័យនោះ។ រឿងមួយដែលគាត់បានស្វែងយល់ដឹងក្នុងចំណោមរឿងជាច្រើននោះ គឺកំណត់ហេតុនៃអង្គប្រជុំគណៈកម្មាធិការមជ្ឈិម ចុះថ្ងៃទី៣០ ខែមិនា ឆ្នាំ១៩៧៦។ ឯកសារដែលគាត់តែងមិនបានលួនេះ មិនសូវច្បាស់លាស់នេះ ក្លាយទៅជាធាតុមួយនៃប្រវត្តិសាស្ត្រដែលគាត់មិនបានដឹងពីមុនមក។[31]*

[31] សៀវភៅរបស់លោក LEMONDE ទំព័រទី៦៩។ សូមអានឧបសម្ព័ន្ធនៃការស្នើសុំនេះ។

៤៦. ម៉្យាងវិញទៀត គឺលោក François PONCHAUD ដែលជាអ្នកស្រោចស្រង់ភាពគួរឲ្យជឿជាក់បាន នៃលោក François BIZOT តាមការយល់ឃើញរបស់អតីតសហចៅក្រមស៊ើបអង្កេត។[32] តាមពិតទៅ លោក LEMONDE "មានការប្រយ័ត្នប្រយែងក្នុងការជឿទៅលើ" សក្ខីកម្មរបស់លោក François BIZOT។[33] បន្ទាប់ពីបានស្តាប់សក្ខីកម្មរបស់លោក François PONCHAUD ដែលគេដឹងថា "គាត់ជាមនុស្សមានការទាមទារខ្ពស់ចំពោះអ្នកដទៃ ក៏ដូចជាជាមួយខ្លួនលោកផ្ទាល់ ហើយមិនងាយនឹងសរសើរអ្នកណាឡើយ" ខាងក្រោមនេះ គឺជាអ្វីដែលលោក អតីតសហចៅក្រមស៊ើបអង្កេតបានសរសេរ៖

> *"ប្រសិនបើលោកចេះបញ្ចោរលោក François BIZOT ខុសពីទម្លាប់ធម្មតាបែបនេះ តើការទិះតៀននោះទៅជាមិនត្រឹមត្រូវទៅហើយ ? មែនទែនទៅ អ្វីដែលគួរឲ្យបារម្ភជាងគេនោះ គឺទម្ងន់នៃការផ្តល់យុត្តិធម៌ចំពោះសក្ខីកម្មរបស់មនុស្ស ៖ ដោយគ្មានភស្តុតាងរូបី ចៅក្រមក៏ធ្វើការសម្រេច ទៅតាមការនិទានដែលលក្ខណៈអត្តនោម័តទាំងស្រុង (បើទោះជាគេធ្វើវាដោយចេតនាល្អក៏ដោយ) ។ រីឯការជឿជាក់លើសាក្សីអាចឲ្យគេវាយតម្លៃផ្សេងៗគ្នា អាស្រ័យដោយសាក្សីនោះត្រូវបានម្នាក់ទៀតបានទិតៀន ឬមិនបានទិតៀន (ដោយគ្មានអ្វីបញ្ជាក់ថា អ្នកនោះគួរឲ្យជឿជាក់ជាង ឬមិនគួរឲ្យជឿជាក់ជាងឡើយ)។ ឬក៏ផ្ទុយមកវិញ សាក្សីនោះត្រូវបានជនទីបី (ដែលគេជឿជាក់ខ្លាំង ដោយសារតែមូលហេតុផ្ទាល់ខ្លួនសុទ្ធសាធ)។ នោះគឺពិតជារឿងគួរឲ្យតក់ស្លុតខ្លាំងណាស់ » ។ [34]*

៤៧. លោក LEMONDE ក៏បានវាយតម្លៃពីការស្តាប់ចម្លើយសាក្សី របស់លោក សួង ស៊ីគឿន និងចម្លើយសាក្សីនៃអតីតភរិយារបស់គាត់។[35] លោកក៏បានធ្វើសេចក្តីសន្និដ្ឋានថា ៖

> *"ទីបញ្ចប់ សក្ខីកម្មរបស់ សួង ស៊ីគឿន ក៏ដូចជាសក្ខីកម្មអតីតប្រពន្ធគាត់ ពិតជាគួរឲ្យខកចិត្តណាស់។ យើងចោទសួរខ្លួនឯងថា អ្វីដែលសល់ពីការផ្តល់សក្ខីកម្មរបស់អ្នកទាំងពីរ តើជារឿងជម្លោះប្តីប្រពន្ធទេដឹង? "[36]*

គ. <u>ការវាយតម្លៃលើភស្តុតាងដទៃទៀត</u>

៤៨. នៅក្នុងស្នាដៃរបស់លោក លោកអតីតសហចៅក្រមស៊ើបអង្កេតបានបង្ហាញពី ការវាយតម្លៃទៅលើភស្តុតាងដទៃទៀត។

---

[32] សៀវភៅរបស់លោក LEMONDE ទំព័រទី១០១-១០៦។ សូមអានឧបសម្ព័ន្ធនៃការស្នើសុំនេះ។

[33] សៀវភៅរបស់លោក LEMONDE ទំព័រទី១០៥។ សូមអានឧបសម្ព័ន្ធនៃការស្នើសុំនេះ។

[34] សៀវភៅរបស់លោក LEMONDE ទំព័រទី១០៦។ សូមអានឧបសម្ព័ន្ធនៃការស្នើសុំនេះ។

[35] សៀវភៅរបស់លោក LEMONDE ទំព័រទី១៦០-១៦៩។ សូមអានឧបសម្ព័ន្ធនៃការស្នើសុំនេះ។

[36] សៀវភៅរបស់លោក LEMONDE ទំព័រទី១៦៨។ សូមអានឧបសម្ព័ន្ធនៃការស្នើសុំនេះ។

៤៩. ខាងក្រោមនេះ គឺជាអ្វីដែលលោកបានសរសេរស្តីពីសេចក្តីថ្លែងការរបស់អតីត "សម្តេចឪ" នរោត្តម សីហនុ ៖

"ពិតណាស់ ខ្ញុំតែងតែចោទសួរអំពីការជួយជ្រោមជ្រែងពិតប្រាកដ ដែលសម្តេចអាចផ្តល់ ដើម្បីស្វែងរកការពិត ព្រោះថាតាំងពីជាងសាមសិបឆ្នាំមកហើយ ព្រះអង្គបង្ហាញឲ្យដឹងថា ទ្រង់អាចប្រកាសថាយ៉ាងនេះ រួចផ្ទុយពីនោះវិញ ចំពោះប្រធានបទគ្រប់បែបយ៉ាង (រួមទាំងឆន្ទៈរបស់ព្រះអង្គក្នុងការចូលរួមផ្តល់សក្ខីកម្មក្នុងតុលាការផង)។ តែថា ព្រះអង្គជាអ្នកតំណាងឲ្យប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជា តាំងពីឆ្នាំ១៩៤១មក។ ដូច្នេះ វាមិនមែនជាការមិនសួរសុខទុក្ខដែលមិនបានស្តាប់ព្រះអង្គមានបន្ទូល ឬក៏មិនបានសាកល្បងនោះ"។[37]

៥០. ម៉្យាងវិញទៀត តាមការយល់ឃើញរបស់លោក LEMONDE ដែលជាអ្នកបានប្រមូលភស្តុតាងរាប់ឆ្នាំមកហើយនោះ វាជាការគួរឲ្យចាប់អារម្មណ៍ដែលកត់សម្គាល់ឃើញថា សមភាគីជាតិរបស់លោកដែលបានរស់នៅក្នុងរបបខ្មែរក្រហម *"មានសំណាងដោយសារតែបានជួបប្រធានភូមិស្លូតបូត ហើយបានឆ្លងកាត់របបនេះ ដោយមិនបានជួបអំពើឃោរឃៅ»* ។[38]

៥១. សរុបមក សម្រង់អត្ថបទចេញពីស្នាដៃរបស់លោក LEMONDE អាចឲ្យគេវាយតម្លៃបានលើភាពឲ្យជឿជាក់បាននៃភស្តុតាងដែលប្រមូលបានក្នុងពេលធ្វើការស៊ើបអង្កេត ហើយមានអត្ថប្រយោជន៍ដើម្បីស្វែងរកការពិត។

៥២. **អាស្រ័យហេតុនេះ** ក្រុមមេធាវីការពារក្តី លោក ខៀវ សំផន ស្នើសុំឲ្យអង្គជំនុំជម្រះសាលាដំបូង មេត្តា ៖

- **ដាក់បញ្ចូល** ស្នាដៃរបស់លោក LEMONDE[39] ទៅក្នុងការពិភាក្សាដេញដោល និង **ទទួលយក** ស្នាដៃនេះធ្វើជាភស្តុតាង

[37] សៀវភៅរបស់លោក LEMONDE ទំព័រទី១៦៨។ សូមមើល ការស្នើសុំរបស់លោក នួន ជា ឧបសម្ព័ន្ធ ឯកសារ **E189/3/1/7.3**.

[38] សៀវភៅរបស់លោក LEMONDE ទំព័រទី១៦៨។ សូមមើល ការស្នើសុំរបស់លោក នួន ជា ឧបសម្ព័ន្ធ ឯកសារ **E189/3/1/7.3**.

[39] រួមមានសម្រង់ទាំងលាយដែលមាននៅក្នុងឧបសម្ព័ន្ធនៃការស្នើសុំនេះ ឧបសម្ព័ន្ធនៃសំណើសុំរបស់លោក នួន ជា **(E189/3/1/7.1 à E189/3/1/7.4)** ព្រមទាំង ឧបសម្ព័ន្ធនៃការស្នើសុំទី១ **(E280.1 à E280.12)**

- **ពិចារណា** លើអត្ថបទដកស្រង់ទាំងនេះ នៅពេលធ្វើការវាយតម្លៃលើភាពគួរឲ្យជឿជាក់បាននៃភស្តុតាងទាំងអស់ដែលប្រមូលបានក្នុងពេលធ្វើការស៊ើបអង្កេតនេះ
- **កោះហៅ** សាក្សី TCW-383 និងសាក្សី TCW-31 ឲ្យឡើងមកបង្ហាញមុខនៅចំពោះមុខតុលាការ។

| | | |
|---|---|---|
| មេធាវី គង់ សំអុន | ភ្នំពេញ | |
| មេធាវី Anta GUISSÉ | ប៉ារីស | |
| មេធាវី Arthur VERCKEN | ភ្នំពេញ | |
| មេធាវី Jacques VERGÈS | ប៉ារីស | |